## ប្រកាស

## ស្តីពីការកែសម្រួលប្រកាសស្តីពី

## សោហ៊ុយបង្កើនដើមទុនសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល  ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាស អោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា  ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០៦

## ស ំ រេ ច

**ប្រការមួយ.-**

កែសម្រួល ចំណុច ៣.២ ប្រការ ៣ នៃប្រកាសលេខធ៧៩៧-១៤៧ ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីល័ក្ខខ័ណ្ឌសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានដូចខាងក្រោម ÷

**ប្រការ៣ថ្មី.-**

៣.២ថ្មី.រាល់ការបង្កើនដើមទុន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ជាមុន។ ការបង្កើនដើមទុនត្រូវបង់សោហ៊ុយចំនួនសូន្យក្បៀសសូន្យបីភាគរយ (០,០៣%) លើចំនួនប្រាក់ដែលសុំបង្កើន ។

**ប្រការពីរ.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការបី.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៦

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការពីរ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"